**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខ្មែរ**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Dec-2014, 14:49
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតប ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

កញ្ញា អ៊ុំច ស្រីផាត់

លោក ឈឿន មករា

លោក Clément BOSSIS

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ជាភាសាអង់គ្លេស និងភាសាខ្មែរ ("សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ")[1]។

២. ថ្ងៃនេះ មេធាវីការពារក្ដីលោក ខៀវ សំផន ("ចុងបណ្ដឹងសាទុក្ខ") ស្នើសុំពន្យារពេលឆ្លើយតបទៅនឹងសារណានេះ អនុលោមតាមអត្ថបទច្បាប់ជាធរមាន[2]។

៣. ជាក់ស្ដែង សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខរែករៀកអំពីបញ្ហាគតិយុត្តិស្មុគស្មាញសុទ្ធសាធ ទាំងទម្រង់ និងគតិច្បាប់ ដែលមិនទាន់ត្រូវបានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") នៅឡើយ។ លើសពីនេះទៅទៀត ឥឡូវនេះ ចុងបណ្ដឹងសាទុក្ខកំពុងតាក់តែងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ដែលត្រូវបានកំណត់ឲ្យដាក់ត្រឹមថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[3]។

៤. យោងតាមយុត្តិសាស្ត្ររបស់តុលាការកំពូល ភាពស្មុគស្មាញនៃបញ្ហាដែលបានលើកឡើង និងបន្ទុកការងារ អាចជាយុត្តិកម្មសម្រាប់ការលើកពេលចាប់ផ្ដើមគិតកាលកំណត់ឆ្លើយតប ចាប់ពីពេលទទួលបានឯកសារមួយ ជាបីភាសាការងាររបស់តុលាការ ក៏ដូចជាពន្យារកាលកំណត់[4]។

---

[1] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ **F11**។

[2] មាត្រា ៨.២ មាត្រា ៨.៣ និងមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារ នៅ អ.វ.ត.ក, វិធាន ៣៩(២) និងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

[3] សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **F9** ("សេចក្ដីសម្រេច **F9**") កថាខណ្ឌ ២៣។

[4] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលដើម្បីធ្វើសារណាតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ **E116/1/2/1** កថាខណ្ឌ ៦, សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីការពារក្ដី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២០

៥. នៅចំពោះមុខតុលាការពិសេសនានា ចុងបណ្តឹងសាទុក្ខទទួលបានពេលវេលាលើសពីពាក់កណ្តាលបន្តិចនៃពេលវេលាដែលត្រូវបានអនុញ្ញាតជូនម្ចាស់បណ្តឹងសាទុក្ខ ដើម្បីដាក់សារណាតប[5]។

៦. ចុងបណ្តឹងសាទុក្ខសូមបញ្ជាក់ថា ការពន្យារកាលកំណត់នឹងមិនបង្កព្យសនកម្មដល់ភាគីផ្សេងទៀតឡើយ ដោយសារតែមិនមានការអនុញ្ញាតឱ្យឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសារណាតប ហើយសវនាការលើបណ្តឹងសាទុក្ខនឹងមិនត្រូវបានធ្វើ មុនពេលសហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីទាំងពីក្រុម នោះឡើយ[6]។

៧. **អាស្រ័យហេតុនេះ** ចុងបណ្តឹងសាទុក្ខស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- **អនុញ្ញាត** ឱ្យចុងបណ្តឹងសាទុក្ខ ដាក់ចម្លើយតបទៅនឹងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីពេលចុងបណ្តឹងសាទុក្ខដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ពោលគឺគិតចាប់ពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ តទៅ (ប្រសិនបើការបកប្រែសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ ទៅជាភាសាបារាំង ត្រូវបានធ្វើរួចរាល់ មុនកាលបរិច្ឆេទនេះ)។

ឬជាជម្រើសម្យ៉ាងទៀត

- **អនុញ្ញាត** ឱ្យចុងបណ្តឹងសាទុក្ខ ដាក់ចម្លើយតបទៅនឹងសារណារបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីពេលជូនដំណឹងអំពីការបកប្រែជាភាសាបារាំងនៃសារណានេះ ប្រសិនបើការបកប្រែត្រូវបានធ្វើរួចរាល់ ក្រោយថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤)។

---

ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ **E163/5/1/2/1** កថាខណ្ឌ ៧, សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អៀង សារី សុំដាក់បណ្តឹងសាទុក្ខតែជាភាសាអង់គ្លេសសិន ហើយអត្ថបទជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E254/3/1/1.2** កថាខណ្ឌ ៥។

[5] សេចក្តីសម្រេច **F9** កថាខណ្ឌ ២០ កំណត់សម្គាល់ជើងទំព័រលេខ ៣៩ (កថាខណ្ឌ ២៣៖ សហព្រះរាជអាជ្ញាមានរយៈពេល ៦០ ថ្ងៃ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ)។

[6] សេចក្តីសម្រេច **F9** កថាខណ្ឌ ២២ និងកថាខណ្ឌ ២៣។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |